scorocs®

Prove and improve the good you do.™

# ឧបករណ៍ប័ណ្ណដាក់ពិន្ទុភាពក្រីក្រលក្ខណៈសាមញ្ញ ប្រទេសកម្ពុជា

Mark Schreiner

ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ ២០២៣

ឯកសារនេះ និង**ឧបករណ៍ប្រមូលទិន្នន័យ** ជាភាសាខ្មែរមាននៅគេហទំព័រ **scorocs.com**
This document and a **data-collection tool** are in English at **scorocs.com**

ឧបករណ៍វាយតម្លៃភាពក្រីក្រនៃប័ណ្ណដាក់ពិន្ទុភាពក្រីក្រលក្ខណៈសាមញ្ញឈ្មោះ (the *Scorocs® Simple Poverty Scorecard® poverty-assessment tool*) គឺជាមធ្យោបាយដ៏មានតម្លាភាពនិងតម្លៃទាប សម្រាប់កម្មវិធីគាំទ្រដល់ជនក្រីក្រនៅក្នុងប្រទេសកម្ពុជា ដើម្បីស្វែងយល់អំពីអ្នកចូលរួមឱ្យបានកាន់តែប្រសើរជាងមុន ក្នុងគោលបំណងបង្ហាញនិងលើកកម្ពស់ការប្រព្រឹត្តិនៅក្នុងសង្គមរបស់ពួកគេ៖ ការឆ្លើយតបទៅនឹងសំណួរទាំង ១០ របស់ប័ណ្ណដាក់ពិន្ទុនេះអាចយកទៅប្រើដើម្បី៖

- ពិនិត្យមើលអត្រានៃភាពក្រីក្រ និងចំនួនប្រជាជនក្រីក្រក្នុងចំណោមអ្នកដែលមកចូលរួម
- តាមដានការផ្លាស់ប្តូរនៃភាពក្រីក្រក្នុងចំណោមអ្នកដែលកំពុងបន្តចូលរួម
- បែងចែកអ្នកចូលរួមជាផ្នែកដើម្បីការព្រឹត្តិផ្សេងៗពីគ្នាផ្អែកលើភាពក្រីក្រី

## កំណត់សម្គាល់អំពីកំណែឧបករណ៍

ប័ណ្ណដាក់ពិន្ទុថ្មីនេះគឺផ្អែកទៅលើទិន្នន័យ ឆ្នាំ **២០១៩/២០២០** ។ វាជំនួសឱ្យប័ណ្ណដាក់ពិន្ទុចាស់ ដែលផ្អែកលើទិន្នន័យឆ្នាំ **២០០៤** **២០១១** និង **២០១៧** ។ ចាប់ពីពេលនោះទៅលោកអ្នកអាចប្រើប្រាស់ប័ណ្ណដាក់ពិន្ទុថ្មីនេះ ព្រោះថាកម្ពុជាបានផ្លាស់ប្តូរនិយមន័យភាពក្រីក្ររបស់ខ្លួននៅឆ្នាំ ២០១៩។ ក្នុងករណីនេះយើងមិនអាចធ្វើការប្រៀបធៀបអាត្រានៃភាពក្រីក្រដែលគណនាដោយប័ណ្ណដាក់ពិន្ទុថ្មីនេះ ជាមួយនិងប័ណ្ណដាក់ពិន្ទុចាស់បានទៀតទេ។

## ថ្លែងអំណាគុណ

**សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា** (CMA) គឺជាអ្នកផ្តល់មូលនិធិសំរាប់ធ្វើប័ណ្ណដាក់ពិន្ទុថ្មីនេះ។ សូមថ្លែងអំណរគុណចំពោះ លោក ផាន សុធា និង លោក វង្ស ភគីនី។ ទិន្នន័យនេះ**ទទួលបានពីវិទ្យាស្ថានជាតិស្ថិតិរបស់ប្រទេសកម្ពុជា**។

“Scorocs” and “Simple Poverty Scorecard” are Registered Trademarks (and “Prove and improve the good you do” is a  Trademark) of Scorocs, LLC for its brand of poverty-assessment tools. Copyright © 2023 Scorocs.

# ឧបករណ៍ប័ណ្ណដាក់ពិន្ទុភាពក្រីក្រលក្ខណៈសាមញ្ញ

| | | | **ឈ្មោះ** | **លេខសម្គាល់** |
|---|---|---|---|---|
| លេខសម្គាល់ការសម្ភាសន៍ ៖ | | | | |
| កាលបរិច្ឆេទសម្ភាសន៍ ៖ | | អ្នកចូលរួមក្នុងកំណត់ត្រា ៖ | | |
| ប្រទេស ៖ | KHM | ភ្នាក់ងារចុះដល់កន្លែង ៖ | | |
| ប័ណ្ណដាក់ពិន្ទុ ៖ | 004 | ទីតាំងសេវាកម្ម ៖ | | |
| ការថ្លឹងសំណាកអោយស្របទៅនិងស្ថានភាពប្រជាជន ៖ | | នួនសមាជិកគ្រួសារ ៖ | | |

| សំណួរ | ចម្លើយ | ន្ទុ |
|---|---|---|
| ១. តើគ្រួសារនេះរស់នៅក្នុងខេត្តណា? (សូមធ្វើការកត់ត្រាដោយមិនចាំបាច់សួរសំណួរ) | ក. ភ្នំពេញ ត្បូងឃ្មុំ កំពង់ធំ ប៉ៃលិន មណ្ឌលគិរី ឬ រតនគិរី | 0 |
| | ខ. កណ្ដាល សៀមរាប បន្ទាយមានជ័យ កំពង់ឆ្នាំង ក្រចេះ ឬ ព្រះវិហារ | ១ |
| | គ. ព្រៃវែង បាត់ដំបង កំពង់ចាម តាកែវ ស្វាយរៀង ពោធិ៍សាត់ ឧត្តរមានជ័យ ឬ ស្ទឹងត្រែង | ២ |
| | ឃ. កំពង់ស្ពឺ ព្រះសីហនុ កំពត កោះកុង ឬ កែប | ៧ |
| ២. តើក្នុងផ្ទះនេះមានសមាជិកប៉ុន្មាននាក់? (សន្លឹកឯកសារទំព័រខាងខ្នង) | គ. ប្រាំពីរ ឬច្រើនជាងនេ | 0 |
| | ខ. ប្រាំមួយ | ៦ |
| | គ. ប្រាំ | ១៣ |
| | ឃ. បួន | ១៨ |
| | ង. បី | ២២ |
| | ច. មួយឬពីរ | ៣០ |
| ៣. តើមានបន្ទប់ចំនួនប៉ុន្មានក្នុងផ្ទះនេះដែលត្រូវបានប្រើប្រាស់ដោយគ្រួសារ (មិនរាប់បញ្ចូលនូវផ្ទះបាយ បង្គន់ និងបន្ទប់ទឹក)? | ក. មួយបន្ទប់ | 0 |
| | ខ. ពីរបន្ទប់ | ៤ |
| | គ. បីបន្ទប់ ឬច្រើនជាងនេ | ៩ |
| ៤. តើអ្វីជាសម្ភារៈសំណង់ចម្បងរបស់កម្រាលនៃលំនៅដ្ឋានដែលគ្រួសារកំពុងរស់នៅ? | ក. បន្ទះឫស្សី ឬដី ឬដីឥដ្ឋ ឬបន្ទះឈើ | 0 |
| | ខ. ស៊ីម៉ងត៍ / ឥដ្ឋ / ថ្ម ឬក្ដារក្រាល ឬឈើប៉ូលា ឬថ្មប៉ូលា ឬថ្មម៉ាប ឬផ្សេងទៀត | ២ |
| | គ. ការ៉ូប្រភេទប្លាស្ទិក ឬការ៉ូ សេរ៉ាមិច | ៤ |
| ៥. តើប្រភេទបង្គន់អនាម័យណាមួយដែលគ្រួសារប្រើប្រាស់រាល់ថ្ងៃ? | ក. មិនមានបង្គន់ប្រើប្រាស់ទេ | 0 |
| | ខ. បង្គន់ចាក់ទឹក បង្ហូរទៅកាន់ធុងស្តុកទឹកស្អុយ ឬរណ្ដៅ ឬកន្លែងផ្សេងទៀតដែលមិនមែនជាប្រពន្ធលូ។ បង្គន់អនាម័យដែលមានឬគ្មានគម្រប ឬក៏ជារណ្ដៅបើក ឬបង្គន់ដាក់នៅវាល ឬលើទឹក (ទម្លាក់ទៅចោលនៅវាល ស្រះ ទន្លេ បឹង ឬសមុទ្រ) ឬក៏ ផ្សេងទៀត | ៣ |
| | គ. បង្គន់ចាក់ទឹក បង្ហូរទៅកាន់លូទឹក | ៤ |
| ៦. តើផ្ទះនេះមានចង្រ្កានហ្គាស ឬចង្រ្កានអគ្គិសនីប្រើប្រាស់ដែរឬទេ? | ក. មិនមាន | 0 |
| | ខ. មាន | ៣ |
| ៧. សរុប តើនៅក្នុងផ្ទះនេះមានទូរស័ព្ទដៃប្រើប្រាស់ប៉ុន្មានគ្រឿង? | ក. គ្មាន ឬមួយគ្រឿង។ | 0 |
| | ខ. ពីរ ឬបីគ្រឿង | ៣ |
| | គ. បួន គ្រឿង ឬច្រើនជាងនេ | ៧ |
| ៨. សរុប តើនៅក្នុងផ្ទះនេះ មានម៉ូតូប៉ុន្មានគ្រឿង (រាប់បញ្ចូលទាំងម៉ូតូអគ្គិសនី ឬម៉ូតូប្រើអាគុយ)? | ក. គ្មានទេ | 0 |
| | ខ. មានមួយគ្រឿង | ៦ |
| | គ. មានពីរគ្រឿង ឬច្រើនជាងនេ | ១២ |
| ៩. តើនៅក្នុងផ្ទះនេះ មានរថយន្តសំរាប់ប្រើប្រាស់ដែរឬទេ? | ក. មិនមាន | 0 |
| | ខ. មាន | ២០ |
| ១០. ក្នុងរយៈពេល ៧ ថ្ងៃកន្លងមកនេះ តើមាននរណាក្នុងផ្ទះនេះបានហូបចេក ផ្លែប៉ោម ក្រូច ក្រូចឆ្មា ឬក្រូចឃ្វិចដែរឬទេ? | ក. មិនមាន | 0 |
| | ខ. មាន | ៤ |


Copyright © 2023 Scorocs.
**Score:**

# សន្លឹកឯកសារទំព័រខាងខ្នង

ជាដំបូងសូមបំពេញផ្នែកខាងលើនៃប័ណ្ណដាក់ពិន្ទុ។ សូបដាក់លេខសម្គាល់ការសម្ភាសន៍ (ប្រសិនបើមាន), កាលបរិច្ឆេទសម្ភាសន៍, ការថ្លឹងសំណាកអោយស្របទៅនិងស្ថានភាពប្រជាជន (ប្រសិនបើមាន)។ បន្ទាប់មកសូមសរសេឈ្មោះ និង លេខសម្គាល់ សំរាប់អ្នកតបសម្ភាសន៍ដែលចូលរួមក្នុងកម្មវិធីរបស់អ្នក (គាត់អាចមិនមែនជាអ្នកតបសម្ភាសន៍), សំរាប់ភ្នាក់ងារដែលធ្វើការជាមួយអ្នកចូលរួមក្នុងកម្មវិធីរបស់អ្នក (គាត់អាចមិនមែនជាអ្នកសម្ភាសន៍), និងសំរាប់ទីតាំងស្នាក់នៅរបស់អ្នកចូលរួមក្នុងកម្មវិធី (ប្រសិនបើដឹង)។ សូមសង្កេត រួចគូសរង្វង់លើខេត្តក្នុងសំណួរទីមួយនៃប័ណ្ណដាក់ពិន្ទុ។

បន្ទាប់មកសូមអាន៖ សូមប្រាប់ឈ្មោះ ឬឈ្មោះហៅក្រៅរបស់សមាជិកក្នុងផ្ទះរបស់អ្នក ដោយចាប់ផ្តើមពី មេគ្រួសារ និង ប្តីឬប្រពន្ធរបស់គាត់ (ប្រសិនបើមាន)។ ផ្ទះ/គ្រួសារ គឺមនុស្សម្នាក់ ឬជាក្រុមមនុស្ស (ដោយមិនគិតពីការជាប់សាច់ឈាមឬមិនជាប់ឡើយ) ដែលរស់នៅជាមួយគ្នាក្រោមដំបូលតែមួយ ហើយហូបចុករួមគ្នាពីចង្ក្រានតែមួយ។ សមាជិកគ្រួសារមិនអាចមានទីស្នាក់នៅផ្សេងក្រៅពីផ្ទះនេះឡើយ ហើយយ៉ាងហោចណាស់គឺបាស្នាក់នៅ ឬមានផែនការស្នាក់នៅផ្ទះនេះរយៈពេល ១២ ខែ។ អ្នកធ្វើចំណាកស្រុក ឬទៅធ្វើការ ក៏អាចរាប់បញ្ចូលជាសមាជិកក្នុងផ្ទះដែរ ប្រសិនបើគាត់មកផ្ទះវិញយ៉ាងហោចណាស់ម្តងក្នុងមួយខែ។

សូមកត់ត្រាឈ្មោះ ឬឈ្មោះហៅក្រៅ របស់សមាជិកក្នុងផ្ទះទាំងអស់ ដោយចាប់ផ្តើមពីមេគ្រួសារ និងប្តីឬប្រពន្ធរបស់គាត់ (ប្រសិនបើមាន)។ ចូរកត់ត្រាភេទរបស់មេគ្រួសារ និងភេទរបស់ប្តីឬប្រពន្ធរបស់គាត់ (ប្រសិនបើមាន)។

បន្ទាប់មក ចូរកត់ត្រាចំនួនសមាជិកទាំងអស់ក្នុងគ្រួសារ រួចកត់ត្រាចំនួនជាក់លាក់នៃសមាជិកទាំងអស់ នៅផ្នែកខាងលើនៃប័ណ្ណដាក់ពិន្ទុ នៅជិត “ចំនួនសមាជិកក្នុងផ្ទះ”។ បន្ទាប់មក គូសរង្វង់ជុំវិញចម្លើយរបស់សំណួរទីពីរ ក្នុងសំណួរនៃប័ណ្ណដាក់ពិន្ទុ។

អានឲ្យលឺៗនូវសំណួរទាំងប្រាំបីដែលនៅសល់ និងបន្តអនុវត្តរាល់ការណែនាំទាំងអស់ដែលមាននៅក្នុងផ្នែក ការណែនាំអំពីការសម្ភាសន៍។

| រាឈ្មោះ ឬឈ្មោះហៅក្រៅ? | មេគ្រួសារ ឬប្តីឬប្រពន្ធរបស់មេគ្រួសារ? |
|---|---|
| ១. | មេគ្រួសារ (ប្រុស)<br>មេគ្រួសារ (ស្រី) |
| ២. | ប្រពន្ធចាស់ជាងគេរបស់ប្តីជាមេគ្រួសារប្តី<br>របស់ស្ត្រីជាមេគ្រួសារ<br>សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៣. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៤. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៥. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៦. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៧. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៨. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ៩. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ១០. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ១១. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| ១២. | សមាជិកក្នុងគ្រួសារផ្សេងទៀត |
| **នួនសមាជិកគ្រួសារ ៖** | |

# ការណែនាំអំពីការសម្ភាសន៍

អត្ថបទដកស្រង់នៅក្នុងការណែនាំអំពីការសម្ភាសន៍ទីនេះបានមកពី៖

ទ្យាស្ថានជាតិស្ថិតិ. (២០១៩) *ឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១៩* [ននៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១៩]

និង

ទ្យាស្ថានជាតិស្ថិតិ. (២០១២) *ឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ* ២០១២, [ននៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១២], តំណ

និង

ទ្យាស្ថានជាតិស្ថិតិ. (២០២០) *ជំរឿនទូទៅនៃប្រជាជនកម្ពុជា* [*ជំរឿន*], តំណ

និង

ទ្យាស្ថានជាតិស្ថិតិ. (២០១៩) “Household Questionnaire: Cambodia Socio-Economic Survey 2019”, [*កម្រងសំណួរ*], តំណ ។

## ១. ការណែនាំអំពីការសម្ភាសន៍ជាមូលដ្ឋាន

អ្នកសម្ភាសអាចបំពេញប័ណ្ណដាក់ពិន្ទុពីក្រដាសនៅពេលចុះសម្ភាស ដោយបញ្ចូលចម្លើយនៅពេលក្រោយទៅក្នុងតារាងឯកសារ ឬនៅក្នុងឃ្លាំងទិន្នន័យផ្ទាល់របស់អ្នក។ ជាជម្រើស ឧបករណ៍ប្រមូលទិន្នន័យដែលផ្អែកលើប្រព័ន្ធអ៊ីនធឺណិតរបស់ Scorocs ដំណើរការជាមួយនឹងកម្មវិធីបើកគេហទំព័រ ដែលជាការផ្តល់លទ្ធភាពដល់ការបញ្ចូលទិន្នន័យបានពីកន្លែងចុះសម្ភាស ឬនៅក្នុងការិយាល័យ។ ប្រសិនបើមិនមានការតភ្ជាប់បណ្តាញទេនោះ ទិន្នន័យនឹងត្រូវបានរក្សាទុកនៅក្នុងឧបករណ៍រហូតទាល់តែមានបណ្តាញតភ្ជាប់។

ប័ណ្ណដាក់ពិន្ទុនេះត្រូវតែបំពេញដោយអ្នកសម្ភាសន៍ដែលទទួលបានការបណ្តុះបណ្តាលក្នុងការអនុវត្តតាមការណែនាំអំពីការសម្ភាសន៍នេះ។

+ពេញផ្នែកខាងលើនៃប័ណ្ណដាក់ពិន្ទុ និងផ្នែក<u>សន្លឹកឯកសារទំព័រខាងខ្នង</u> ជាមុនសិន បន្ទាប់មកធ្វើតាមការណែនាំដែលកំណត់ឲ្យ។

នៅក្នុងផ្នែកខាងលើនៃប័ណ្ណដាក់ពិន្ទុ សូមបំពេញចំនួនរបស់សមាជិកក្នុងផ្ទះដាក់លាក់ក្នុងចន្លោះ “នួនសមាជិកគ្រួសារ” ដែលផ្អែកទៅលើបញ្ជីដែលអ្នកសម្ភាសន៍ បានបង្កើតឡើងនៅ<u>សន្លឹកឯកសារទំព័រខាងខ្នង</u>។

ដូចគ្នានិងសំណួរខាងលើដែរ សូមកុំសួរសំណួរទីពីរក្នុងផ្នែកប័ណ្ណដាក់ពិន្ទុ ទៅកាន់អ្នកចូលរួមឡើយ (“តើផ្ទះនេះមានសមាជិកប៉ុន្មាននាក់?”) ។ ផ្ទុយទៅវិញ សូមគូសចំណាំតាមរយៈចម្លើយដែលអ្នកចូលរួមផ្តល់អោយ អំពីចំនួននៃសមាជិកក្នុងផ្ទះ ដែលអ្នកបានកត់ចំណាំនៅ<u>សន្លឹកឯកសារទំព័រខាងខ្នង</u>។

សួរសំណួរទាំងប្រាំបីដែលនៅសេសសល់ដោយផ្ទាល់ទៅកាន់អ្នកតបសម្ភាសន៍។

សូមអានសំណួរម្តងមួយៗ អោយបានច្បាស់តាមលំដាប់លំដោយដែលបានដាក់ក្នុងប័ណ្ណដាក់ពិន្ទុ

កុំអានចម្លើយ។

សូមអានអំពីសេចក្តីណែនាំនេះអោយចេះ ហើយយកវាទៅជាមួយអ្នកពេលដែលអ្នកចុះធ្វើការ។ សូមធ្វើតាមការណែនាំក្នុងឯកសារនេះជានិច្ច (រួមទាំងមួយនេះផង)។

ចូរចងចាំថា អ្នកតបសម្ភាសន៍នៅក្នុងការសម្ភាសន៍នេះមិនចាំបាច់តែជាសមាជិកក្នុងផ្ទះ ដែលជាអ្នកចូលរួមក្នុងកម្មវិធីរបស់អ្នកនោះទេ ។

ដូចគ្នានេះផងដែរ ភ្នាក់ងារដែលត្រូវកត់ត្រាចូលផ្នែកខាងលើនៃប័ណ្ណដាក់ពិន្ទុ ក៏អាចជាមនុស្សផ្សេងពីអ្នកសម្ភាសន៍ដែរ។ ផ្ទុយទៅវិញ ភ្នាក់ងារគឺជាបុគ្គលិករបស់កម្មវិធីគាំទ្រជនក្រីក្រ ដែលមានទំនាក់អំនងការងារជាមួយអ្នកចូលរួម ។ ប្រសិនបើមិនមាន ឬ អ្នកមិនដឹងថាមានភ្នាក់ងារទេនោះ ចូរសរសេរថា “គ្មាន” ឬ “មិនដឹង“ នៅក្នុងកន្លែងដែលពាក់ព័ន្ធ ក្នុងផ្នែកខាងលើនៃប័ណ្ណដាក់ពិន្ទុ។

ជាទូទៅ កុំទុកចន្លោះទទេនៅផ្នែកខាងលើ។ ប្រសិនបើមិនដឹងព័ត៌មានដែលបានស្នើសុំនោះ ឬ មិនមាន ឬមិនអាចយកជាការបាន សូមសរសេរ “មិនដឹង“ ឬ “គ្មាន“ នៅក្នុងចន្លោះទទេនោះ។ នេះបង្ហាញថាអ្នកដែលជាអ្នកសម្ភាសន៍បានព្យាយាមដើម្បីទទួលបាននូវទិន្នន័យ។ វាអាចជួយជៀសវាងការត្រលប់ទៅផ្ទះនោះវិញម្តងទៀតនៅពេលក្រោយ ដើម្បីព្យាយាមប្រមូលទិន្នន័យដែលមិនអាចប្រមូលបាននៅពេលនោះ។

ពេលអ្នកគូសចម្លើយមួយនៅលើសំណួរក្នុងប័ណ្ណដាក់ពិន្ទុ ត្រូវសរសេរចំនួនពិន្ទុនៅក្នុងក្រឡោន “ពិន្ទុ“ ហើយ បន្ទាប់មកគូសរង្វង់ជុំវិញជម្រើសចម្លើយដែលមានសរសេរ ចំនួនពិន្ទុដែលមានស្រាប់ និងពិន្ទុដោយការសរសេរដៃ ដូច្នេះ៖

| | | | |
|---|---|---|---|
| ៧. សរុប តើនៅក្នុងផ្ទះនេះមានទូរស័ព្ទដៃប្រើប្រាស់ប៉ុន្មានគ្រឿង? | ក. គ្មាន ឬមួយគ្រឿង។ | 0 | |
| | ខ. ពីរ ឬបីគ្រឿង | ៧ | ៧ |
| | គ. បួន គ្រឿង ឬច្រើនជាងនេ | ១១ | |

នៅពេលដែលកើតមានបញ្ហាដែលត្រូវដោះស្រាយ ប៉ុន្តែឯកសារណែនាំអំពីការសម្ភាសន៍នេះ មិនមានចែងអំពីវិធីសាស្ត្រដែលត្រូវប្រើដើម្បីដោះស្រាយ នោះអ្នសម្ភាសន៍អាចរកដំណោះស្រាយតាមរយៈការវិនិច្ឆ័យរបស់អ្នកសម្ភាសន៍ជាក់ស្តែង នេះក៏ជាការអនុវត្តន៍នៅពេល ស្ទង់មតិសង្គម-សេដ្ឋកិច្ចនាឆ្នាំ ២០១៩/២០២០ ដែរ។ ពោលគឺ កម្មវិធីមួយមិនគួរកំណត់វិន័យណាមួយទៅលើការសម្ភាសន៍ឡើយ (ក្រៅពីនិយមន័យ និងច្បាប់វិន័យដែលមាននៅក្នុង ឯកសារណែនាំអំពីការសម្ភាសន៍នេះ) ដើម្បីឱ្យអ្នកសម្ភាសន៍របស់កម្មវិធីប្រើទាំងអស់គ្នានោះទេ។ អ្វីក៏ដោយដែលមិនត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងឯកសារណែនាំអំពីការសម្ភាសន៍នេះទេ គឺត្រូវទុកអោយអ្នកសម្ភាសន៍ជាអ្នកធ្វើការវិនិច្ឆ័យដោយផ្ទាល់ និង អ្នកតបសម្ភាសន៍ ។

កុំអានជម្រើសចម្លើយទៅកាន់អ្នកតបសម្ភាសន៍អោយសោះ។ សូមអានតែសំណួរប៉ណ្ណោះ បន្ទាប់មកឈប់ ហើយរង់ចាំចម្លើយពីអ្នកតបសម្ភាសន៍។ ប្រសិនបើអ្នកតបសម្ភាសន៍សួរ បញ្ជាក់ ឬ មើលទៅគាត់ហាក់ដូចជាមិនច្បាស់អំពីសំណួរទេនោះ ឬហាក់ដូចជាច្រឡំ នោះ សូមអានសំណួរម្តងទៀត ឬក៏ផ្តល់ជំនួយបន្ថែមផ្អែកលើឯកសារណែនាំអំពីការសម្ភាសន៍នេះ ឬ តាមការយល់ឃើញដោយសមស្របរបស់អ្នកសម្ភាសន៍។

ជាទូទៅ អ្នកគួរទទួលយកចម្លើយអ្វីក៏ដោយ អោយតែជាចម្លើយដែលអ្នកតបសម្ភាសន៍បានផ្តល់ឲ្យ។ ប៉ុន្តែប្រសិនបើអ្នកតបសម្ភាសន៍ផ្តល់ចម្លើយដែលមិនច្បាស់លាស់ ប្រហែលជាមិនត្រឹមត្រូវ ឬ ក៏គាត់មិនច្បាស់អំពីចម្លើយដែលគាត់ផ្តល់អោយ ឬក៏មើលទៅគាត់ហាក់ដូចជាមិនច្បាស់អំពីសំណួរ អ្នកគួរតែអានសំណួរម្តងទៀតអោគាត់ស្តាប់ ឬជួយគាត់អោយយល់តាមតែអាចធ្វើទៅបានដូចដែលមានចែងក្នុងឯកសារសេចក្តីណែនាំអំពីការសម្ភាសន៍។

ជាទូទៅចម្លើយនៅក្នុងសំណួរជាច្រើនរបស់ប័ណ្ណដាក់ពិន្ទុនេះមិនត្រូវការការបញ្ជាក់បន្ថែមអំពីចម្លើយនោះទេ។ អ្នកត្រូវការធ្វើការបញ្ជាក់បន្ថែមលុះត្រាណាតែអ្នកគិតថាការផ្តល់ចម្លើយរបស់អ្នកតបសម្ភាសន៍ហាក់ដូចជាមិនត្រឹមត្រូវ ហើយការបញ្ជាក់បន្ថែមរបស់អ្នកអាចនឹងជួយធ្វើអោយគុណភាពទិន្នន័យមានភាពប្រសើរឡើង។ ឧទាហរណ៍៖ អ្នកតបសម្ភាសន៍មានភាពស្ទាក់ស្ទើរក្នុងការឆ្លើយតប មានភាពភ័យ មានភាពមិនច្បាស់លាស់ ឬក៏មើលទៅគាត់ហាក់បីដូចជាច្រឡំ ឬមិនច្បាស់អំពីសំណួរដែលអ្នកសួរទៅកាន់គាត់។

ដូចគ្នានេះដែរ ប្រសិនបើក្មេងៗនៅក្នុងផ្ទះ ឬ ញាតិជិតចាងនិយាយអ្វីមួយដែលខុសពីចម្លើយដែលអ្នកតបសម្ភាសន៍ផ្តល់អោយ លោកអ្នកប្រហែលជាត្រូវធ្វើការផ្ទៀងផ្ទាត់។ ការផ្ទៀងផ្ទាត់អាចកាន់តែល្អប្រសើ ប្រសិនជាអ្នកអាចមើលឃើញដោយផ្ទាល់ ហើយដឹងថាចម្លើយដែលអ្នកតបសម្ភាសន៍ផ្តល់អោយគឺមិនត្រឹមត្រូវ ដូចជាទ្រព្យសម្បត្តិផ្សេងៗដែលអ្នកតបសម្ភាសន៍បានអះអាងថាមិនមានជាកម្មសិទ្ធិរបស់គាត់ ឬមានការភ្លេចរាប់បញ្ចូលកុមារណាម្នាក់ជាសមាជិកនៅក្នុងគ្រួសារ។

ជាទូទៅ ការប្រើប្រាស់ប័ណ្ណដាក់ពិន្ទុគួរតែអនុវត្តតាមកម្មវិធីស្ទង់មតិសង្គម-សេដ្ឋកិច្ចឆ្នាំ ២០១៩/២០២០ ដោយវិទ្យាស្ថានជាតិស្ថិតិកម្ពុជា តាមដែលអាចធ្វើទៅបាន។ ឧទាហរណ៍៖ ការសម្ភាសន៍ គួរតែធ្វើឡើងដោយផ្ទាល់ជាដោយអ្នកសម្ភាសន៍ដែលបានឆ្លងកាត់ការបណ្តុះបណ្តាលត្រឹមត្រូវ នៅឯលំនៅឋានរបស់អ្នកចូលរួម ព្រោះថានោះគឺជាអ្វីដែលវិទ្យាស្ថានជាតិស្ថិតិបានធ្វើនៅក្នុងការស្ទង់មតិសង្គម-សេដ្ឋកិច្ចនាឆ្នាំ ២០១៩/២០២០។

## ២. ការបកប្រែ

អ្នកសម្ភាសន៍គួរធ្វើការសម្ភាសន៍ជាភាសាដែលអ្នកនិងអ្នកតបសម្ភាសន៍និយាយយល់គ្នាបានល្អ។

ប័ណ្ណដាក់ពិន្ទុ សន្លឹកឯកសារទំព័រខាងខ្នង និង ការណែនាំអំពីការសម្ភាសន៍ គឺមានទាំងជាភាសាអង់គ្លេស និងជាភាសាខ្មែរ។ ពុំទាន់មានការបកប្រែជាផ្លូវការដំទៃទៀតដែលប្រើប្រាស់នៅក្នុងប្រទេសកម្ពុជានៅឡើយទេ។ អ្នកប្រើប្រាស់គួរតែពិនិត្យនៅ **scorocs.com** ដើម្បីមើលថាតើមានការបកប្រែជាភាសាអ្វីខ្លះ ដែលបានធ្វើឡើង។ ប្រសិនបើពុំទាន់មានការបកប្រែជាផ្លូវការលើភាសាដែលអ្នកចង់ប្រើទេនោះ សូមទំនាក់ទំនងទៅកាន់ **Scorocs** ដើម្បីរៀបចំសហការគ្នា។

## ៣. តើអ្នកណាគួរតែជាអ្នកតបសម្ភាសន៍?

ចូរចងចាំថា អ្នកតបសម្ភាសន៍មិនចាំបាច់តែជាសមាជិកគ្រួសារ ដែលជាអ្នកចូលរួមក្នុងកម្មវិធីរបស់អ្នកឡើយ។

យោងតាមទំព័រទី ២ នៃ*កម្រងសំណួរ*"គេគួរតែសួរសំណួរទៅកាន់មេគ្រួសារ ប្ដីឬប្រពន្ធរបស់មេគ្រួសារ ឬប្រសិនបើទាំងមេគ្រួសារ និងប្ដីឬប្រពន្ធរបស់មេគ្រួសារមិនមានវត្តមាន ត្រូវសួរសមាជិកជាមនុស្សពេញវ័យម្នាក់ទៀតនៅក្នុងគ្រួសារ"។

យោងតាមទំព័រទី ១០ នៃនៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១២ "គួរតែត្រូវបានបំពេញដោយមានជំនួយពីមេគ្រួសារ និងសមាជិកគ្រួសារផ្សេងទៀតតាមតម្រូវការ។ ប្រសិនបើមេគ្រួសារ មិនមានវត្តមានទេ អាចសម្ភាសន៍សមាជិកដែលជំនួសមេគ្រួសារ ឬ សួរសមាជិកជាមនុស្សពេញវ័យម្នាក់ទៀតនៅក្នុងគ្រួសារ"។

យោងតាមទំព័រទី ៨ នៃនៃកូនសៀវណៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១២ អ្នក អាចសម្ភាសន៍សមាជិកគ្រួសារណាម្នាក់នៅក្នុងគ្រួសារ ជាអ្នកដែលអាចផ្ដល់ចម្លើយយ៉ាងត្រឹមត្រូវទៅនិងសំណួរ និងអាចផ្ដល់ព័ត៌មានលំអិតអំពីផ្ទះនោះបាន។ មេគ្រួសារ និង/ឬប្តីឬប្រពន្ធ គឺជាជនដែលមានលក្ខណៈសម្បត្តិសមស្របបំផុតក្នុងការឆ្លើយតប។

យោងតាមទំព័រទី ២៤ នៃនៃកូនសៀវណៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១២ "គួរតែសួរសំណួរទៅមេគ្រួសារ រឺប្តីឬប្រពន្ធរបស់មេគ្រួសារ។ ប្រសិនបើវាមិនអាចប្រើកម្រងសំណួរដើម្បីសួរទៅកាន់មនុស្សណាម្នាក់នៃបុគ្គលទាំងនោះទេ (ឧទាហរណ៍៖ ពីព្រោះពួកគេទាំងពីរមិនមានវត្តមាន) នោះគេអាចប្រើកម្រងសំណួរជាមួយមនុស្សពេញវ័យម្នាក់ទៀតដែលជាសមាជិកនៅក្នុងគ្រួសារ ដែលមានចំណេះដឹងគ្រប់គ្រាន់។

## ៤. តើនណាជាមេគ្រួសារ?

មេគ្រួសារអាចជា ឬអាចមិនមែនជាសមាជិកគ្រួសារ ដែលជាអ្នកចូលរួមនៅក្នុងកម្មវិធីរបស់អ្នក។

យោងតាមទំព័រទី ១៨៦ នៃនៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១៩ "មេគ្រួសារគឺជាសំដៅចំពោះសមាជិកក្រុមគ្រួសារដែលត្រូវបានទទួលស្គាល់និងយល់ព្រមដោយសមាជិកក្រុមគ្រួសារដទៃទៀតថាជាមេគ្រួសារ។ ក្រុមគ្រួសារជាច្រើនតែងយល់ព្រមនិងទទួលស្គាល់ថា ឪពុកគឺជាមេគ្រួសារ។ ប៉ុន្តែប្រការនេះមិនគួរអោយពិបាកពេកទេ ហើយក៏មានត្រូវសន្មត់ ឬប៉ាន់ស្មានឡើយ។ ដូច្នេះ សំខាន់គឺគ្រាន់តែសួរអ្នកតបសម្ភាសន៍ថា តើអ្នកណាជាមេគ្រួសារ គឺជាការស្រេចហើយ។"

យោងតាមទំព័រទី ១៨៦ នៃជំរឿន "រាប់គោលបំណងជំរឿន មេគ្រួសារគឺជាមនុស្សដែលត្រូវបានទទួលស្គាល់ពីសមាជិកគ្រួសារ។ មេគ្រួសារជាប្រុស ឬស្រី ជាទូទៅគាត់ជាអ្នកទទួលខុសត្រូវក្នុងការគ្រប់គ្រងគ្រួសារ និងធ្វើការសម្រេចចិត្តក្នុងនាមអោយគ្រួសារ។ មេគ្រួសារ មិនចាំបាច់តែជាមនុស្សចាស់ទេ ប៉ុន្តែគាត់អាចជាស្រី ក្មេងស្រី ឬក្មេងប្រុសនៃសមាជិកគ្រួសារ។ ឈ្មោះអ្នកដែលត្រូវទទួស្គាល់នៅក្នុងគ្រួសារថាជាមេគ្រួសារ ត្រូវបានរាយការណ៍នៅក្នុងជំរឿន។ សម្រាប់គោលបំណងជំរឿន ក្នុងករណីអវត្តមានមេគ្រួសារ អ្នកផ្សេងដែលទទួលខុសត្រូវក្នុងការចាត់ចែងគ្រប់គ្រងការងារទាំងអស់របស់មេគ្រួសារត្រូវបានចាត់ទុកថាជាមេគ្រួសារ។"

ក្នុងផ្ទះនីមួយៗមានមេគ្រួសារតែមួយគត់ (គឺមានតែមួយគត់)។ មេគ្រួសារនៃគ្រួសារដែលត្រូវបានសម្ភាសន៍ត្រូវតែជាសមាជិកនៃគ្រួសារដែលតបសម្ភាសន៍។ បុគ្គលម្នាក់មិនអាចធ្វើជាមេគ្រួសារលើសពីមួយផ្ទះបានទេ ព្រោះគ្មាននរណាម្នាក់អាចជាសមាជិកគ្រួសារលើសពីមួយផ្ទះបានឡើយ។

# គោលការណ៍ណែនាំសម្រាប់សំណួរនីមួយៗក្នុងប័ណ្ណដាក់ពិន្ទុ

## ១. តើគ្រួសារនេះរស់នៅក្នុងខេត្តណា?

ក. ភ្នំពេញ ត្បូងឃ្មុំ កំពង់ធំ ប៉ៃលិន មណ្ឌលគិរី ឬ រតនគិរី

ខ. កណ្ដាល សៀមរាប បន្ទាយមានជ័យ កំពង់ឆ្នាំង ក្រចេះ ឬ ព្រះវិហារ

គ. ព្រៃវែង បាត់ដំបង កំពង់ចាម តាកែវ ស្វាយរៀង ពោធិ៍សាត់ ឧត្ដរមានជ័យ ឬ ស្ទឹងត្រែង

ឃ. កំពង់ស្ពឺ ព្រះសីហនុ កំពត កោះកុង ឬ កែប

លុះត្រាតែមានការចាំបាច់! សូមកុំសួរសំណួរនេះដោយផ្ទាល់ទៅកាន់អ្នកតបសម្ភាសន៍។ ផ្ទុយទៅវិញ បំពេញចម្លើយផ្អែកទៅលើការយល់ដឹងរបស់អ្នកអំពីខេត្តដែលគ្រួសាររស់នៅ។

## ២. តើក្នុងផ្ទះនេះមានសមាជិកប៉ុន្មាននាក់?

គ. ប្រាំពីរ ឬច្រើនជាងនេ
ខ. ប្រាំមួយ
គ. ប្រាំ
ឃ. បួន
ង. បី
ច. មួយឬពីរ

យោងតាមទំព័រទី ១៨៦ នៃជំរឿន, "ជាក្រុមមនុស្សមួយក្រុមដែលរស់នៅរួមគ្នា និងហូបចុកអាហារចេញពីចង្ក្រានតែមួយ វៀលែងតែអ្នកដែលមានការងារពិសេសមិនអាចទៅហូបចុកជាមួយបាន។"

សូមកុំសួរសំណួរនេះដោយផ្ទាល់ទៅកាន់អ្នកតបសម្ភាសន៍។ ផ្ទុយទៅវិញ គូសចំណាំចម្លើយផ្អែកទៅលើចំនួននៃសមាជិកគ្រួសារអ្នកជាអ្នកសម្ភាសន៍ចុះក្នុងបញ្ជីនៅលើ សន្លឹកឯកសារទំព័រខាងខ្នង។

យោងតាមទំព័រទី ១៨៦ នៃនៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១៩ "ផ្ទះ/គ្រួសារ គឺជា ក្រុមមនុស្សមួយក្រុម (ឬបុគ្គលម្នាក់)ដែលជាទូទៅរស់នៅរួមគ្នា និងហូបអាហាររួមជាមួយគ្នា ដូចជាការប្រើប្រាស់ផ្ទះបាយរួម ឬថវិកាលើអាហាររួម។ បុគ្គលទាំងនោះអាចជាសាច់ញាតិនិងគ្នា ឬអាចមិនមែនជាសាច់ញាតិ និងរួមទាំងអ្នកបម្រើ ឬបុគ្គលិក ឬកម្មករផ្សេងទៀតដែលស្នាក់នៅជាមួយនិយោជក។"

យោងតាមទំព័រទី ២៦ នៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១២ "សិស្ស អ្នកមកស្នាក់នៅជាមួយ និងបុគ្គលិក ដែលរស់នៅក្នុងលំនៅស្ថានរបស់គ្រួសារ និងដែលមានការរៀបចំចំណីអាហាររួមជាមួយនឹងគ្រួសារ ត្រូវចាត់ទុកថាជា សមាជិកក្នុងផ្ទះ ប្រសិនបើពួកគេបានរស់នៅក្នុងផ្ទះនោះលើសពីរយៈពេលមួយឆ្នាំ ឬប្រសិនបើពួកគេមិនមានកន្លែងស្នាក់នៅដទៃទៀត។

"ទោះយ៉ាងណាក្តី ប្រសិនបើមានអ្នកមកស្នាក់នៅជាមួយ/អ្នកស្នាក់អាស្រ័យចំនួនប្រាំនាក់ ឬច្រើនជាងនេះក្នុងលំនៅដ្ឋានមួយ នោះពួកគេមិនគួរត្រូវបានរាយការណ៍ថាជាសមាជិកក្នុងផ្ទះនេះឡើយ ដែលពួកគេបង់ប្រាក់បន្ទប់និងចំណីអាហារទៅឱ្យនោះទេ។"

យោងតាមទំព័រទី ២៧ នៃនៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១២ “សមាជិកគ្រួសារមួយ គឺជាបុគ្គលទាំងឡាយណា ដែលបានរស់នៅជាធម្មតាក្នុង លំនៅដ្ឋានរបស់គ្រួសារដែលត្រូវបានសម្ភាសន៍ ហើយដែលមានការហូបចុករួមគ្នាអស់រយៈ ពេលយ៉ាងហោចណាស់មួយឆ្នាំ ឬអ្នកដែលមិនមានលំនៅដ្ឋានដទៃទៀត។

“ដូច្នេះហើយ សិស្សភាគច្រើនដែលទៅសិក្សានៅសាលាឆ្ងាយពីផ្ទះត្រូវបានចាត់ទុកថាជា សមាជិកគ្រួសាររបស់ពួកគេ ជាជាងសមាជិកគ្រួសារ ដែលនៅជិត សាលារបស់ពួកគេ លុះ ត្រាតែពួកគេបានស្នាក់នៅជាបន្តបន្ទាប់ជាមួយគ្រួសារដែលនៅជិតសាលារបស់ពួកគេនោះរ យៈពេលយូរជាងមួយឆ្នាំ។

“បុគ្គលម្នាក់ដែលបានផ្លាស់ទីលំនៅថ្មីៗ (ពោលគឺ តិចជាងមួយឆ្នាំ) ត្រូវបានចាត់ទុកថាជា សមាជិករបស់គ្រួសារ នៅទីតាំងរស់នៅរបស់គេ ប្រសិនបើគេមិនមានគម្រោងត្រលប់មកកាន់ គ្រួសារពីមុនវិញក្នុងរយៈពេលមួយឆ្នាំទេនោះ។ ស្រដៀងគ្នានេះដែរ បុគ្គលម្នាក់ដែលបាន ផ្លាស់ទីលំនៅចេញពីគ្រួសារមួយថ្មីៗ ដោយមិនមានបំណងត្រលប់មកវិញទេនោះ គឺលែងត្រូវ បានចាត់ទុកថាជាសមាជិកក្នុងគ្រួសារ នោះទៀតហើយ។

“បុគ្គលម្នាក់ត្រូវបានរាប់ថាជា សមាជិកគ្រួសារ ប្រសិនបើគេរស់នៅទីនោះ ឬអវត្តមានតិចជាង រយៈពេល ១២ ខែ។

បុគ្គលដែលបានចាកចេញពីគ្រួសារដែលត្រូវបានសម្ភាសន៍យូរជាងរយៈពេលមួយឆ្នាំ និងនៅ តែមកលេងគ្រួសារដែលត្រូវបានសម្ភាសន៍ត្រឹមតែម្តងម្កាល (ដូចជាសម្រាប់តែពេលថ្ងៃបុណ្យ ជាតិសំខាន់ៗ ដែលមានពីរបីដងក្នុងមួយឆ្នាំ) មិនត្រូវបានចាត់ទុកថាជា សមាជិករបស់គ្រួសារ ដែលបានសម្ភាសន៍នោះទេ។ ទោះជាយ៉ាងណា បុគ្គលដែលមានលំនៅដ្ឋានដាច់ដោយឡែក អស់រយៈពេលយូរជាងមួយឆ្នាំ ប៉ុន្តែមកលេងផ្ទះទៀងទាត់ (ជាធម្យម ម្តងក្នុងមួយខែ ឬញឹក ញាប់ជាងនេះទៀត) នៅតែត្រូវចាត់ទុកថាជាសមាជិករបស់គ្រួសារដែលត្រូវបានសម្ភាសន៍ (ឧទាហរណ៍ កម្មកររោងចក្រកាត់ដេរ) ។

“ប្តីប្រពន្ធទើបរៀបការណ៍ថ្មីថ្មោង (ឧទាហរណ៍ ៖ កូនប្រសារប្រុស ឬ កូនប្រសារស្រី) ដែលទើប តែបានចូលរួមក្នុងគ្រួសារ កុមារទើបកើត ឬសមាជិកគ្រួសារដែលធ្វើដំណើរពីភូមិមួយទៅភូមិ មួយទៀតដើម្បីធ្វើការ ឬជាអ្នកដែលត្រលប់មកផ្ទះវិញយ៉ាងទៀងទាត់ពីកន្លែងធ្វើការ (សម្រាប់ ចុងសប្តាហ៍ ឬពេលខ្លះ នៅចុងខែ ដូចជាកម្មកររោងចក្រកាត់ដេរ) ត្រូវបានចាត់ទុកថាជា សមាជិករបស់គ្រួសារដែលបានសម្ភាសន៍។

“អ្នកទើបរៀការថ្មីថ្មោង ដែលបានផ្លាស់លំនៅចេញពីគ្រួសារដែលត្រូវបានសម្ភាសន៍ មនុស្ស ដែលបានស្លាប់ជាដើម មិនត្រូវរាប់បញ្ចូលជា សមាជិកធម្មតានៃគ្រួសារនោះទេ។

## ៣. តើមានបន្ទប់ចំនួនប៉ុន្មានក្នុងផ្ទះនេះដែលត្រូវបានប្រើប្រាស់ដោយគ្រួសារ (មិនរាប់បញ្ចូលនូវផ្ទះបាយ បង្គន់ និងបន្ទប់ទឹក)?

ក. មួយបន្ទប់
ខ. ពីរបន្ទប់
គ. បីបន្ទប់ ឬច្រើនជាងនេ

យោងតាមទំព័រទី ៣៥ នៃនៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១២ "សូមសួររកចំនួនបន្ទប់ក្នុងលំនៅដ្ឋាន ដែលគ្រួសារត្រូវបានសម្ភាសន៍នោះប្រើ។ បន្ទប់មួយត្រូវតែមានជញ្ជាំងបួន ដំបូល និងទ្វារចេញ ហើយ វាត្រូវតែធំល្មម និងវែងល្មមសម្រាប់មនុស្សម្នាក់ដេកខាងក្នុងបាន។ ពេលរាប់ចំនួនបន្ទប់ដែលប្រើប្រាស់ដោយគ្រួសារដែលត្រូវបានសម្ភាសន៍ អ្នកគួរតែដកផ្ទះបាយ បន្ទប់ដាក់អីវ៉ាន់ បន្ទប់ទឹក និងបង្គន់ចេញ ព្រោះថាបន្ទប់ទាំងនេះជាទូទៅមិនត្រូវបានប្រើសម្រាប់ការរស់នៅ ឬដេកនោះទេ។ បន្ទប់មួយដែលប្រើរួមដោយគ្រួសារច្រើនជាងមួយ មិនត្រូវរាប់ថា បានកាន់កាប់ដោយគ្រួសារដែលបានប្រើរួមណាមួយនោះឡើយ។"

## ៤. តើអ្វីជាសម្ភារៈសំណង់ចម្បងរបស់កម្រាលនៃលំនៅដ្ឋានដែលគ្រួសារកំពុងរស់នៅ?

ក. បន្ទះឫស្សី ឬដី ឬដីឥដ្ឋ ឬបន្ទះឈើ
ខ. ស៊ីម៉ងត៍ / ឥដ្ឋ / ថ្ម ឬក្ដារក្រាល ឬឈើប៉ូលា ឬថ្មប៉ូលា ឬថ្មម៉ាប ឬផ្សេងទៀត
គ. ការ៉ូប្រភេទប្លាស្ទិក ឬការ៉ូ សេរ៉ាមិច

យោងតាមទំព័រទី ៣៥ នៃឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យនាំឆ្នាំ ២០១២ សំណួរនេះអាចត្រូវបានឆ្លើយតាមរយៈការសង្កេត។ ប៉ុន្តែ ប្រសិនបើមានការសង្ស័យ នោះចូរសួរសំទៅអ្នកតបសម្ភាសន៍។

ប្រសិនបើផ្ទៃបាត (កម្រាល) នៃលំនៅដ្ឋានរបស់គ្រួសារដែលត្រូវបានសម្ភាសន៍ ធ្វើពីវត្ថុធាតុច្រើនជាងមួយប្រភេទ នោះ កត់ត្រាប្រភេទវត្ថុធាតុដែលជាចំណែកផ្ទៃបាត (កម្រាល) នៃលំនៅដ្ឋានច្រើនជាងគេ។

## ៥. តើប្រភេទបង្គន់អនាម័យណាមួយដែលគ្រួសារប្រើប្រាស់រាល់ថ្ងៃ?

ក. មិនមានបង្គន់ប្រើប្រាស់ទេ

ខ. បង្គន់ចាក់ទឹក បង្ហូរទៅកាន់ធុងស្តុកទឹកស្អុយ ឬរណ្តៅ ឬកន្លែងផ្សេងទៀតដែលមិនមែនជាប្រពន្ធលូ។ បង្គន់អនាម័យដែលមានឬគ្មានគម្រប ឬក៏ជារណ្តៅបើក ឬបង្គន់ដាក់នៅវាល ឬលើទឹក (ទម្លាក់ទៅចោលនៅវាល ស្រះ ទន្លេ បឹង ឬសមុទ្រ) ឬក៏ផ្សេងទៀត

គ. បង្គន់ចាក់ទឹក បង្ហូរទៅកាន់លូទឹក



**ក. បត់ជើងនៅវាល (មិនមានបង្គន់ប្រើប្រាស់ទេ)**



ខ. បង្គន់ចាក់ទឹក បង្ហូរទៅកាន់ធុងស្តុកទឹកស្អុយ ឬរណ្តៅ ឬកន្លែងផ្សេងទៀតដែលមិនមែនជាប្រពន្ធល



ខ. បង្គន់ចាក់ទឹក បង្ហូរទៅកាន់ធុងស្តុកទឹកស្អុយ ឬរណ្តៅ ឬកន្លែងផ្សេងទៀតដែលមិនមែនជាប្រពន្ធល



ខ. បង្គន់ចាក់ទឹក បង្ហូរទៅកាន់ធុងស្តុកទឹកស្អុយ ឬរណ្តៅ ឬកន្លែងផ្សេងទៀតដែលមិនមែនជាប្រពន្ធល



ខ. បង្គន់អនាម័យដែលមានឬគ្មានគម្រប ឬក៏ជារណ្តៅបើក ឬបង្គន់ដាក់នៅវាល ឬលើទឹក
(ទម្លាក់ទៅចោលនៅវាល ស្រះ ទន្លេ បឹង ឬសមុទ្រ)



ខ. បង្គន់អនាម័យដែលមានឬគ្មានគម្រប ឬក៏ជារណ្តៅបើក ឬបង្គន់ដាក់នៅវាល ឬលើទឹក
(ទម្លាក់ទៅចោលនៅវាល ស្រះ ទន្លេ បឹង ឬសមុទ្រ)



ខ. បង្គន់អនាម័យដែលមានឬគ្មានគម្រប ឬក៏ជារណ្តៅបើក ឬបង្គន់ដាក់នៅវាល ឬលើទឹក
(ទម្លាក់ទៅចោលនៅវាល ស្រះ ទន្លេ បឹង ឬសមុទ្រ)



គ. បង្គន់ចាក់ទឹក ឬ (ចុចបង្ហូរទឹក) តភ្ជាប់ទៅប្រព័ន្ធលូ

## ៦. តើផ្ទះនេះមានចង្ក្រានហ្គាស ឬចង្ក្រានអគ្គីសនីប្រើប្រាស់ដែរឬទេ?

ក. មិនមាន

ខ. មាន

យោងតាមវិទ្យាស្ថានជាតិស្ថិតិ ចង្ក្រានអគ្គិសនី ឬចង្ក្រានហ្គាសដែលខូចប៉ុន្តែអាចជួសជុលបាន គួរតែត្រូវរាប់បញ្ចូលសម្រាប់គោលបំណងនៃសំណួរនេះ។ ចង្ក្រានអគ្គិសនី ឬចង្ក្រានហ្គាសដែលខ្ចីគេមិនគួររាប់បញ្ចូលនោះទេ។

ឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យ ឆ្នាំ ២០១២ មិនបានផ្តល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

## ៧. សរុប តើនៅក្នុងផ្ទះនេះមានទូរស័ព្ទដៃប្រើប្រាស់ប៉ុន្មានគ្រឿង?

ក. គ្មាន ឬមួយគ្រឿង។
ខ. ពីរ ឬបីគ្រឿង
គ. បួន គ្រឿង ឬច្រើនជាងនេ

យោងតាមវិទ្យាស្ថានជាតិស្ថិតិ ទូរស័ព្ទដៃលខូចប៉ុន្តែអាចជួសជុលបាន គួរតែត្រូវរាប់បញ្ចូល សម្រាប់គោលបំណងនៃសំណួរនេះ។ ទូរស័ព្ទដៃលខ្ចីគេមិនគួររាប់បញ្ចូលនោះទេ។

ឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យ ឆ្នាំ ២០១២ មិនបានផ្តល់ជូន ព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

### ៨. សរុប តើនៅក្នុងផ្ទះនេះ មានម៉ូតូប៉ុន្មានគ្រឿង (រាប់បញ្ចូលទាំងម៉ូតូអគ្គីសនី ឬម៉ូតូប្រើអាគុយ)?

ក. គ្មានទេ
ខ. មានមួយគ្រឿង
គ. មានពីរគ្រឿង ឬច្រើនជាងនេ

យោងតាមវិទ្យាស្ថានជាតិស្ថិតិ ម៉ូតូដែលខូចប៉ុន្តែអាចជួសជុលបាន គួរតែត្រូវរាប់បញ្ចូល សម្រាប់គោលបំណងនៃសំណួរនេះ។ ម៉ូតូដែលខ្ចីគេមិនគួររាប់បញ្ចូលនោះទេ។

ឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យ ឆ្នាំ ២០១២ មិនបានផ្តល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

## ៩. តើនៅក្នុងផ្ទះនេះ មានរថយន្តសំរាប់ប្រើប្រាស់ដែរឬទេ?

ក. មិនមាន

ខ. មាន

យោងតាមវិទ្យាស្ថានជាតិស្ថិតិ រថយន្តដែលខូចប៉ុន្តែអាចជួសជុលបាន គួរតែត្រូវរាប់បញ្ចូលសម្រាប់គោលបំណងនៃសំណួរនេះ។ រថយន្តដែលខ្ចីគេមិនគួររាប់បញ្ចូលនោះទេ។

ឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យ ឆ្នាំ ២០១២ មិនបានផ្តល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។

## ១០. ក្នុងរយៈពេល ៧ ថ្ងៃកន្លងមកនេះ តើមាននរណាក្នុងផ្ទះនេះបានហូបចេក ផ្លែប៉ោម ក្រូច ក្រូចឆ្មា ឬក្រូចឃ្វិចដែរឬទេ?

ក. មិនមាន

ខ. មាន

ឯកសារណែនាំសម្រាប់ មន្ត្រីសម្ភាសន៍ និង មន្ត្រីត្រួតពិនិត្យ ឆ្នាំ ២០១២ មិនបានផ្តល់ជូនព័ត៌មានបន្ថែមសម្រាប់សំណួរនេះទេ។